គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ : ០៧៥/១៧ គ.ជ.ប.ជ

# កំណត់ហេតុកិច្ចប្រជុំ
## ស្តីពីការផ្សព្វផ្សាយបង្ហាញលទ្ធផលការវាយតម្លៃពាក់កណ្តាលអាណត្តិ
## នៃផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
## រយៈពេល ០៥ឆ្នាំ ២០១៤-២០១៨
## ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៧

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែឧសភា ថ្ងៃទីបី វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក នៅទីស្តីការក្រសួងមហាផ្ទៃ មានបើកកិច្ចប្រជុំអន្តរក្រសួង ស្តីពីការផ្សព្វផ្សាយបង្ហាញលទ្ធផលការវាយតម្លៃពាក់កណ្តាលអាណត្តិ នៃផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ០៥ឆ្នាំ ២០១៤-២០១៨ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។**

សមាសភាពចូលរួមកិច្ចប្រជុំសរុបចំនួន **៧៧រូប (ស្រី ២២រូប)** រួមមានតំណាងមកពី ក្រសួងមហាផ្ទៃ ក្រសួងព័ត៌មាន ក្រសួងការបរទេស ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការងារ ក្រសួងធម្មការនិងសាសនា ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងវប្បធម៌ ក្រសួងកិច្ចការនារី ក្រសួងកសិកម្ម ក្រសួងឧស្សាហកម្ម ក្រសួងអប់រំ ក្រសួងប្រៃសនីយ៍ ក្រសួងសង្គមកិច្ច ក្រសួងទេសចរណ៍ ក្រសួងសុខាភិបាល ទីស្តីការគណៈរដ្ឋមន្ត្រី អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម កងរាជអាវុធហត្ថផ្ទៃប្រទេស ទីចាត់ការការងារព្រំដែន អង្គការ GVC, CARE, IJM, ADB, World Vision, Cambodia Acts, O.Institute, WI, Ratanak, IOM, UN-ACT, KYA, LSCW, ADHOC, ACILS/SC, Winrock, CCPCR, APLE, Hagar, AAPTIP និង ChabDai ។

គោលបំណងនៃកិច្ចប្រជុំគឺ ក្រុមការងារស្រាវជ្រាវវាយតម្លៃរបស់អង្គការ WINROCK INTERNATIONAL បង្ហាញអំពីលទ្ធផលស្រាវជ្រាវ និងការវាយតម្លៃពាក់កណ្តាលអាណត្តិ នៃផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ០៥ឆ្នាំ ដើម្បីឲ្យក្រុមការងារអន្តរក្រសួង និងអង្គការពាក់ព័ន្ធ ធ្វើការត្រួតពិនិត្យ និងកែសម្រួល ដើម្បីឲ្យលទ្ធផលនៃការវាយតម្លៃកាន់តែមានភាពសុក្រឹត្យ និងឯកភាពគ្នា ។

ជាកិច្ចចាប់ផ្តើម តំណាងអង្គការ WINROCK Int. បានឡើងធ្វើបទបង្ហាញអំពីលទ្ធផលស្រាវជ្រាវ និងការវាយតម្លៃ ដែលមានដូចខាងក្រោម ៖

### ការប្រព្រឹត្តទៅនៃយន្តការ

| ផែនការសម្រាប់ការអនុវត្ត ការសម្របសម្រួលការធ្វើផែនការ និងការត្រួតពិនិត្យ និងការវាយតម្លៃ | ការវាយតម្លៃ | | |
|---|---|---|---|
| | ការរីកចម្រើនមានកម្រិត | ការរីកចម្រើនតាមផែនការ | ការរីកចម្រើនគួរឲ្យកត់សម្គាល់ |
| ១.យន្តការត្រួតពិនិត្យ និងវាយតម្លៃនៃការអនុវត្តផែនការសកម្មភាពជាតិជាផ្លូវការ បង្កើតឡើងដោយមានការចូលរួមពីភាគីពាក់ព័ន្ធ | ● | | |

| | | | |
|---|---|---|---|
| ២.សមត្ថភាពនៃមន្ត្រីទទួលខុសត្រូវទាំងអស់នៅគ្រប់លំដាប់ថ្នាក់ត្រូវបានពង្រឹង | | | ● |
| ៣.ឧបករណ៍សម្រាប់ត្រួតពិនិត្យ និងវាយតម្លៃត្រូវបានបង្កើតឡើង និងបានប្រើប្រាស់ | ● | | |
| ៤.ការវាយតម្លៃទិន្នន័យដែលប្រមូល និងទិន្នន័យដែលផ្សព្វផ្សាយ | | | ● |
| ៥.របាយការណ៍សមិទ្ធិផលនៃការអនុវត្តសកម្មភាពប្រឆាំងការជួញដូរដែលចេញផ្សាយប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆ្នាំ ដោយការវាស់ស្ទង់នូវសមិទ្ធិផលតបនឹងសូចនាករ | ● | | |

## **សមិទ្ធិផលនានានៃការអនុវត្តផែនការសកម្មភាពជាតិ**

| យុទ្ធសាស្ត្រទី ១<br>ការពង្រឹងច្បាប់ និងគោលនយោបាយ និងលើកកំពស់កិច្ចសហប្រតិបត្តិការ | ការវាយតម្លៃ<br>ការរីកចម្រើនមានកម្រិត | ការវាយតម្លៃ<br>ការរីកចម្រើនតាមផែនការ | ការវាយតម្លៃ<br>ការរីកចម្រើនគួរឲ្យកត់សម្គាល់ |
|---|---|---|---|
| ១.យន្តការជាតិសម្រាប់ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សបានកែលម្អ និងពង្រឹងដោយមានការចូលរួមយ៉ាងទូលំទូលាយ និងធនធានមនុស្សគ្រប់គ្រាន់សម្រាប់ការអនុវត្តច្បាប់ និងការពង្រឹងគោលនយោបាយល្អប្រសើរជាងមុន ហើយនិងការបង្កើនកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ | | ● | |
| ២.កិច្ចព្រមព្រៀងអនុស្សរណៈនៃការយោគយល់ទ្វេភាគី និងពហុភាគី និងលិខិតបទដ្ឋានដ៏ទៃទៀតដែលទាក់ទងនឹងការជួញដូរមនុស្ស ការកេងប្រវ័ញ្ចពលកម្ម និងផ្លូវភេទបានអនុវត្តដោយភាគីពាក់ព័ន្ធជាមួយនឹងការទទួលខុសត្រូវច្បាស់លាស់ និងលទ្ធផលដែលអាចវាស់វែងបាន | | ● | |
| ៣.ច្បាប់ គោលនយោបាយថ្មីដែលចាំបាច់ ផែនការសកម្មភាពជាតិ និងអន្តរជាតិសម្រាប់ការប្រឆាំងរាល់ទម្រង់នៃការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទ និងពលកម្មត្រូវបានអនុវត្តរួមគ្នា ត្រួតពិនិត្យ និងវាយតម្លៃ ហើយបានធ្វើឲ្យមានប្រសិទ្ធិភាពដោយការកំណត់ និងដោះស្រាយបញ្ហាចន្លោះប្រហោង | | | ● |

| យុទ្ធសាស្ត្រទី ២<br>លើកកម្ពស់ការបង្ការទប់ស្កាត់ | ការវាយតម្លៃ<br>ការរីកចម្រើនមានកម្រិត | ការវាយតម្លៃ<br>ការរីកចម្រើនតាមផែនការ | ការវាយតម្លៃ<br>ការរីកចម្រើនគួរឲ្យកត់សម្គាល់ |
|---|---|---|---|
| ១.យុទ្ធសាស្ត្របង្ការទប់ស្កាត់ត្រូវបានរៀបចំ និងអនុវត្តដើម្បីដោះស្រាយផងដែរនូវតម្រូវការនៃការជួញដូរ ដោយផ្តោតលើការផ្លាស់ប្តូរឥរិយាបថបុគ្គល និងសហគមន៍ | | | ● |
| ២.និន្នាការ ផលប៉ះពាល់ និងការគ្រប់គ្រងនៃការធ្វើចំណាកស្រុករបស់ពលករចំណាកស្រុកត្រូវបានត្រួតពិនិត្យ ដើម្បីលើកកម្ពស់ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការពារសិទ្ធិ និងផលប្រយោជន៍កម្មករនៅគ្រប់ដំណាក់កាលនៃការធ្វើចំណាកស្រុក | | ● | |

| យុទ្ធសាស្ត្រទី ៣<br>ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបនឹងការជួញដូរមនុស្ស | ការវាយតម្លៃ<br>ការរីកចម្រើនមានកម្រិត | ការវាយតម្លៃ<br>ការរីកចម្រើនតាមផែនការ | ការវាយតម្លៃ<br>ការរីកចម្រើនគួរឲ្យកត់សម្គាល់ |
|---|---|---|---|
| ១.ចំណេះដឹង និងសមត្ថភាពក្នុងការប្រើឧបករណ៍ច្បាប់ក្នុងចំណោមស្ថាប័នតុលាការក្នុងការកាត់ទោសករណីជួញដូរមនុស្សត្រូវពង្រឹង | | ● | |

| | | | |
|---|---|---|---|
| ២.សម្របសម្រួលក្នុងចំណោមការអនុវត្តច្បាប់ ប្រព័ន្ធតុលាការ និងសេវាសង្គមសម្រាប់ការស៊ើបអង្កេត និងកាត់ទោសនៃករណីការជួញដូរមនុស្ស ការរត់ពន្ធពលកម្ម និងការធ្វើអាជីវកម្មផ្លូវភេទនៅកម្ពុជា (STSLS) ធ្វើឲ្យបានប្រសើរឡើង | | | ● |

| <u>យុទ្ធសាស្ត្រទី ៤</u><br>ការការពារជនរងគ្រោះជាមួយនឹងយេនឌ័រ និងអាយុ ប្រកបដោយការគាំទ្រគុណភាពសមស្រប | ការវាយតម្លៃ | | |
|---|---|---|---|
| | ការរីកចម្រើនមានកម្រិត | ការរីកចម្រើនតាមផែនការ | ការរីកចម្រើនគួរឲ្យកត់សម្គាល់ |
| ១.ជនរងគ្រោះនៃការជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្មត្រូវបានជួយសង្គ្រោះបញ្ជូនមកវិញ បានស្តារនីតិសម្បទា ធ្វើសមាហរណកម្ម និងទទួលបានសេវាសមស្របពេញលេញ និងគុណភាព តម្រូវតាមយេនឌ័រ អាយុ និងតម្រូវការ | | | ● |
| ២.ការសម្របសម្រួល និងការសហការគ្នាក្នុងចំណោមអ្នកផ្តល់សេវាទាំងមិនមែនរដ្ឋាភិបាល និងរដ្ឋាភិបាលក្នុងការផ្តល់សេវាទាន់ពេលវេលាដែលមានប្រសិទ្ធិភាពផលិតផលល្អដល់សេវាគាំទ្រជនរងគ្រោះត្រូវបានរួមបញ្ចូល | | | ● |

បន្ទាប់មក លោកស្រី វ៉ូប៊ីន ម៉ូនី អ្នកប្រឹក្សាយោបល់ និងជាប្រធានក្រុមស្រាវជ្រាវ បានមានប្រសាសន៍ថា យើងមានលទ្ធផល និងរចនាសម្ព័ន្ធហើយ ដូចនេះជំហានបន្ទាប់គឺត្រូវជម្រុញនូវយុទ្ធសាស្ត្រថ្មីៗដើម្បីឲ្យការអនុវត្តកាន់តែមានប្រសិទ្ធិភាព ។ មួយវិញទៀត ទិន្នន័យយើងមានហើយ តែលទ្ធភាពនៃការប្រមូលផ្តុំទិន្នន័យទាំងនោះនៅមានកម្រិត ព្រោះមិនមានប្រព័ន្ធរាយការណ៍រួម ដូចនេះអ្នកពាក់ព័ន្ធទាំងអស់ត្រូវរាយការណ៍ និងផ្តល់ទិន្នន័យឲ្យបានច្បាស់លាស់ ដើម្បីមានមូលដ្ឋានច្បាស់លាស់សម្រាប់ធ្វើផែនការសកម្មភាពជំហានបន្ទាប់ ។ ជំហានបន្ទាប់គឺត្រូវរៀបចំប្រព័ន្ធទិន្នន័យ និងត្រូវធ្វើការជាមួយគ្នាដើម្បីទទួលបានទិន្នន័យច្បាស់លាស់ និងការវាយតម្លៃសុក្រឹត្យ ។ លោកស្រីបានសុំឲ្យអង្គប្រជុំធ្វើការពិនិត្យការវាយតម្លៃ និងរង់ចាំស្តាប់មតិយោបល់ដើម្បីធ្វើការកែសម្រួល ។

- **<u>មតិយោបល់ចូលរួមក្នុងអង្គប្រជុំ</u> ៖**

  **អង្គប្រជុំបានធ្វើការពិភាក្សាដោយយកចិត្តទុកដាក់ ហើយទទួលបានលទ្ធផលដូចខាងក្រោម៖**

  - នៅក្នុងសូចនាករ សរសេរថា "ជនរងគ្រោះ" តែយើងមិនទាន់បានកំណត់អត្តសញ្ញាណ ដូចនេះគួរប្តូរដាក់ថា "ជនសង្ស័យរងគ្រោះ" វិញ ។
  - ធ្វើតាមសូចនាករពេលខ្លះខាតពេល (ឧទាហរណ៍៖ ផែនការគ្រោងទុកតែជាមួយប្រទេសថៃ ឬម៉ាឡេស៊ី តែបញ្ហាកើតថ្មីៗជាមួយចិន ដូចនេះត្រូវធ្វើសកម្មភាពថ្មីៗដើម្បីដោះស្រាយ) ។
  - ចំណុចគួរបន្ថែមគឺ Lesson Learn ព្រោះយើងបានរៀនច្រើនពាក់ព័ន្ធការអនុវត្តច្បាប់ និងបទដ្ឋាន ។
  - លទ្ធផលនៃការវាយតម្លៃនៅមានទិន្នន័យ និងសកម្មភាពមួយចំនួនរបស់ក្រសួង-ស្ថាប័នមិនទាន់ដាក់បញ្ចូល ដែលត្រូវការកែសម្រួល និងបំពេញបន្ថែមឲ្យសព្វជ្រុងជ្រោយ ដូចនេះតំណាងក្រសួង-ស្ថាប័ននីមួយៗបានស្នើសុំយកទៅពិភាក្សាជាមួយក្រុមការងាររបស់ខ្លួនសិន ដើម្បីប្រមូលនូវទិន្នន័យឲ្យបានច្បាស់លាស់ រួចបញ្ជូនមកធ្វើការកែសម្រួលដើម្បីឲ្យលទ្ធផលវាយតម្លៃកាន់តែសុក្រឹត្យ និងឯកភាពគ្នា ។

ជាកិច្ចបន្ត អង្គប្រជុំបានបែងចែកជា ៤ក្រុម ដើម្បីពិភាក្សាពិនិត្យមើលការវាយតម្លៃ បញ្ហាប្រឈម និងស្វែងរកដំណោះស្រាយ និងសកម្មភាពដែលជាអាទិភាពសម្រាប់អនុវត្តនៅពាក់កណ្តាលអាណត្តិក្រោយ ហើយទទួលបានលទ្ធផលដូចខាងក្រោម៖

| បញ្ហាប្រឈម | ដំណោះស្រាយ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| <u>យុទ្ធសាស្ត្រទី ១</u><br>ការពង្រឹងច្បាប់ និងគោលនយោបាយ និងលើកកំពស់កិច្ចសហប្រតិបត្តិការ | | |
| ១.មានការយឺតយ៉ាវក្នុងការប្រមូលរបាយការណ៍ | -ពង្រឹងការរៀបចំ និងផ្តល់របាយការណ៍ | ក្រសួងដឹកនាំក្រុមជំនាញ<br>អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ |
| ២.MOU/SOP ជាមួយប្រទេសមួយចំនួនមានការលើកពេល | -ជំរុញការអនុវត្ត MOU/SOP<br>-ប្រមូល និងចងក្រង MOU/SOP | ក្រសួងការបរទេស<br>អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ |
| ៣.ធនធានសម្រាប់ការអនុវត្តគោលនយោបាយ និង MOU/SOP នៅមានកម្រិត | -បង្កើន និងគៀងគរធនធាន ដើម្បីអនុវត្តន៍MOU/SOP | តាមក្រុមជំនាញ<br>អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ<br>NGOs |
| ៤.កិច្ចសហប្រតិបត្តិការក្នុងការជួយជនរងគ្រោះឆ្លងដែនមានការលំបាក | -ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសគោលដៅ | គ.ជ.ប.ជ<br>ក្រសួងការបរទេស<br>ក្រសួងយុត្តិធម៌<br>វិស័យឯកជន និង NGOs |
| ៥.ជនរងគ្រោះផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ក្នុងការធ្វើចំណាត់ការ | -បង្កើនកិច្ចសហការក្នុងការផ្តល់ព័ត៌មានការធ្វើចំណាកស្រុកដោយសុវត្ថិភាព | តាមក្រុមជំនាញ<br>អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ |
| <u>យុទ្ធសាស្ត្រទី ២</u><br>លើកកម្ពស់ការបង្ការទប់ស្កាត់ | | |
| ១.ការប្រមូលទិន្នន័យនៅមានការយឺតយ៉ាវ ខ្វះធនធានមនុស្ស ខ្វះអ្នកធ្វើរបាយការណ៍ | -ពង្រឹងក្រុមការងារបច្ចេកទេស<br>-ត្រូវការអ្នកបញ្ចូលទិន្នន័យ<br>-ក្រសួងទទួលបន្ទុកប្រជុំសមាជិក<br>-កែសម្រួលការត្រួតពិនិត្យទិន្នន័យ<br>-បណ្តុះបណ្តាលធនធានមនុស្ស | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ក្រសួងការងារ<br>ក្រសួងមហាផ្ទៃ<br>ក្រសួងឧស្សាហកម្ម<br>ក្រសួងអប់រំ<br>ក្រសួងយុត្តិធម៌<br>ក្រសួងការពារជាតិ<br>ក្រសួងកិច្ចការនារី<br>ក្រសួងទេសចរណ៍<br>ក្រសួងកសិកម្ម |
| ២.ខ្វះថវិកាដើម្បីរៀបចំ ខ្វះការគាំទ្រពីដៃគូ (ថវិកា បច្ចេកទេស និងសម្ភារៈ | -រៀបចំយុទ្ធសាស្ត្របង្ការទប់ស្កាត់<br>-ផ្សព្វផ្សាយលិខិតបទដ្ឋានពាក់ព័ន្ធ<br>-ធ្វើការវាយតម្លៃបណ្តុះបណ្តាលជំនាញ<br>-ធ្វើការសិក្សាស្រាវជ្រាវកំណត់ប្រព័ន្ធផ្ទេរប្រាក់ទាំងផ្លូវការ និងមិនផ្លូវការ | ស្ថាប័នធនាគារជាតិ<br>ដៃគូអភិវឌ្ឍន៍ |
| <u>យុទ្ធសាស្ត្រទី ៣</u><br>ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបនឹងការជួញដូរមនុស្ស | | |
| ១. | -ជម្រុញឲ្យមានការអនុម័តចេញប្រកាសអន្តរក្រសួងស្តីពីកិច្ចសហប្រតិបត្តិការរវាងអង្គភាពប្រឆាំងការជួញដូរមនុស្ស និងតុលាការ (នគរបាល ព្រះរាជអាជ្ញា ចៅក្រម) | |

| | | |
|---|---|---|
| | -ជម្រុញច្បាប់ស្តីពីការរត់ពន្ធមនុស្សឲ្យឆាប់អនុម័ត<br>-ជម្រុញធ្វើសេចក្តីព្រាងច្បាប់ស្តីពីការពពោះជំនួស<br>-ជម្រុញការអនុវត្តច្បាប់ស្តីពីជំនួយទៅវិញទៅមក ផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ<br>-ជម្រុញកិច្ចសហប្រតិបត្តិការក្រៅផ្លូវការរវាង ប៉ូលីសថៃ កម្ពុជា និងបណ្តាប្រទេសក្នុងតំបន់ | |
| ២. | -ផ្សព្វផ្សាយ និងបណ្តុះបណ្តាលច្បាប់ជួញដូរមនុស្ស និងល្បិចកលរបស់ជនល្មើស (ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ) | |
| ៣. | -ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ក្នុងការស៊ើបអង្កេត និងផ្តន្ទាទោស<br>-ពង្រឹងគ្រូបង្គោល ជម្រុញការបណ្តុះបណ្តាលសិស្ស សាលារាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ (ឯកសារ ឯកទេសប្រឆាំងការជួញដូរមនុស្សអាស៊ាន)<br>-ជម្រុញការរៀបចំ (កិច្ចជំនួយផ្លូវច្បាប់ទៅវិញទៅមក ក្នុងវិស័យព្រហ្មទណ្ឌ សន្ធិសញ្ញា បត្យាប័ន កិច្ចព្រមព្រៀងស្តីពីការបញ្ជូនទណ្ឌិត រវាងប្រទេសពាក់ព័ន្ធ<br>-ជម្រុញការដឹកនាំ និងការប្រមូលទិន្នន័យ | |
| **យុទ្ធសាស្ត្រទី ៤**<br>**ការការពារជនរងគ្រោះជាមួយនឹងយេនឌ័រ និងអាយុ ប្រកបដោយការគាំទ្រគុណភាពសមស្រប** | | |
| ១.ខ្វះការស្រាវជ្រាវបច្ចុប្បន្នភាពអំពីបញ្ហាកុមារសុំទាន | -រៀបចំផែនការស្រាវជ្រាវអំពីកុមារសុំទាន | ក្រសួងសង្គមកិច្ច |
| ២.ខ្វះប្រព័ន្ធជួយជនរងគ្រោះនៅប្រទេសគោលដៅ ខ្វះការកំណត់អត្តសញ្ញាណ ខ្វះជម្រក ខ្វះការសម្របសម្រួលក្នុងការធ្វើមាតុភូមិនិវត្តន៍ ខ្វះធនធនសម្របសម្រួល | -បង្កើត និងពង្រឹងប្រព័ន្ធជួយជនរងគ្រោះក្នុងប្រទេស | ក្រសួងការបរទេស<br>ស្ថានទូត |
| ៣.ខ្វះធនធានមនុស្ស និងហិរញ្ញវត្ថុក្នុងការជួយជនរងគ្រោះ | -ផ្តល់ការបណ្តុះបណ្តាល និងជ្រើសរើសបំពេញបន្ថែមទៅលើការកំណត់អត្តសញ្ញាណជនរងគ្រោះ និងអន្តរាគមន៍បន្ទាន់ | គ.ជ.ប.ជ<br>ក្រសួងសង្គមកិច្ច<br>ក្រសួងការបរទេស<br>CSOs |
| ៤.ខ្វះធនធានក្នុងការជួយជនរងគ្រោះក្នុងការធ្វើសមាហរណកម្ម | គៀងគរធនធនពីក្រសួង ស្ថាប័នពាក់ព័ន្ធ និង CSOs | គ.ជ.ប.ជ<br>ក្រសួងសង្គមកិច្ច<br>ក្រសួងការបរទេស<br>CSOs |
| ៥.ខ្វះសេវាជំនាញដូចជា ការប្រឹក្សាយោបល់ ផ្នែកផ្លូវចិត្ត និងច្បាប់ | -ផ្តល់អ្នកជំនាញពាក់ព័ន្ធសម្រាប់ការពិគ្រោះយោបល់ | ក្រសួងសង្គមកិច្ច<br>CSOs |
| ៦.ខ្វះមណ្ឌលបណ្តោះអាសន្នដល់ជនរងគ្រោះ | -បង្កើតឲ្យមានមណ្ឌលរបស់រដ្ឋ និងអង្គការ | ក្រសួងសង្គមកិច្ច<br>CSOs |

ជាទីបញ្ចប់ លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានផ្ដល់អនុសាសន៍ណែនាំមួយចំនួនដូចខាងក្រោម៖

- នេះគឺជាការចាប់អារម្មណ៍ដំបូងចំពោះលទ្ធផលស្រាវជ្រាវ អ្វីដែលយើងត្រូវធ្វើគឺពិនិត្យមើលឡើងវិញមានចំណុចណាខ្លះដែលមិនឯកភាព និងត្រូវការកែសម្រួល ព្រោះក្រុមអ្នកស្រាវជ្រាវវាយតម្លៃទៅលើលទ្ធផលដែលគាត់បានមើលឃើញប៉ុណ្ណោះ ។
- សកម្មភាពយើងធ្វើបានច្រើន តែការវាយតម្លៃគឺធ្វើទៅលើតែសកម្មភាពដែលបានគ្រោងទុកប៉ុណ្ណោះ ដូចនេះយើងត្រូវពិនិត្យមើល ថាតើសកម្មភាពដែលបានគ្រោងទុកនោះយើងបានធ្វើ ឬមិនបានធ្វើ ។ ម្យ៉ាងវិញទៀត សកម្មភាពយើងធ្វើបានច្រើនមែន តែការប្រមូលទិន្នន័យគឺមិនបានគ្រប់ជ្រុងជ្រោយឡើយ ព្រោះមិនទាន់មានប្រព័ន្ធរាយការណ៍រួម ។
- ត្រូវពិនិត្យមើលបន្ថែម មើលថាចំណុចណាដើរ ចំណុចណាមិនដើរ ព្រោះអ្វី ហើយត្រូវពង្រឹងបន្ថែម ឬត្រូវដកចេញ និងពិនិត្យមើលអំពីបញ្ហាប្រឈមដែលនៅសេសសល់ ហើយត្រូវរិះរកសកម្មភាពដើម្បីដោះស្រាយ ។ អ្វីដែលប្រឈមខ្លាំងគឺយើងមានច្បាប់ បទដ្ឋានច្រើន តែវានៅរាយប៉ាយ ដូចនេះយើងត្រូវប្រមូលផ្ដុំចងក្រងឡើងវិញ ។
- ក្រសួងនីមួយៗមានផែនការសកម្មភាពរៀងៗខ្លួន តែយើងត្រូវពិនិត្យឡើងវិញថាតើមានសកម្មភាពណាដែលរួមចំណែកក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងតើគោលនយោបាយណាដែលរួមចំណែកជួយប្រជាពលរដ្ឋមិនឲ្យធ្វើចំណាកស្រុក ។
- សូមឯកភាពយោបល់អង្គប្រជុំ ដែលត្រូវការយកទៅពិភាក្សាតាមក្រុមសិន ដើម្បីឲ្យទទួលបានទិន្នន័យច្បាស់លាស់ និងឯកភាពគ្នា ។
- យើងត្រូវធ្វើ MOU ជាមួយប្រទេសដែលនឹងបញ្ជូនពលករទៅ ។
- ចង់ឲ្យមានការផ្សព្វផ្សាយដល់ពលករមុនពេលដែលពួកគាត់ត្រូវមេខ្យល់ជួញដូរ ។
- យើងនឹងជួបប្រជុំគ្នាម្តងទៀត ដើម្បីធ្វើផែនការយុទ្ធសាស្ត្រសម្រាប់ ០៥ឆ្នាំបន្តទៀត ។

បានឃើញ 18/05/17 ជូ ប៊ុនអេង

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោងដប់ប្រាំមួយរសៀល ថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសស្និទ្ធស្នាល និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ។

ភ្នំពេញ ថ្ងៃទី១២ខែឧសភាឆ្នាំ២០១៧

**អ្នកធ្វើកំណត់ហេតុ**

ង.ស្រី ហ៊ុំ.រតនៈ

គោរពជូន លោកជំទាវ
អនុប្រធានអចិន្ត្រៃយ៍ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។
ភ្នំពេញ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧

**ប្រធានលេខាធិការដ្ឋាន**

**ឧត្តមសេនីយ៍ទោ. គង់ ~ ពុទ្ធី**